# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៣៣.សសរ

## សេចក្តីសំរេច
## ស្តីពី ការបង្កើតក្រុមការងារអភិបាលកិច្ច

### រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញ ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញ ព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំង រាជរដ្ឋាភិបាល

-បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/ ០៣៩៩/៧២ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតឧត្តម ក្រុមប្រឹក្សាកំណែទំរង់រដ្ឋ

-បានឃើញ អនុក្រឹត្យលេខ ៥១ អនក្រ.បក ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល

-បានឃើញ អនុក្រឹត្យលេខ ៨៣ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល

-យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

### សំរេច

ប្រការ ១ : ត្រូវបានបង្កើតក្រុមការងារអភិបាលកិច្ច នៅទីស្តីការគណៈរដ្ឋមន្ត្រី ធ្វើជាសេនាធិការផ្ទាល់លើការសំរបសំរួលការងាររបស់ឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ ការអនុវត្តទីផែនការសកម្មភាពអភិបាលកិច្ច និង កម្មវិធីកំណែទំរង់នានារបស់រាជរដ្ឋាភិបាល ។

ប្រការ ២ : ក្រុមការងារនេះ ជាចំណុចប្រមូលផ្តុំសំរាប់តាមដាន សំរបសំរួល និង ធ្វើរបាយការណ៍បូកសរុបការងាររាយការណ៍ជូននាយករដ្ឋមន្ត្រី ដែលជាប្រធានឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ អំពីលទ្ធផល និង បញ្ហាប្រឈម ក្នុងការអនុវត្តនីកម្មវិធីកំណែទំរង់នានា និង ផែនការសកម្មភាពអភិបាលកិច្ចរបស់រាជរដ្ឋាភិបាល ។

ប្រការ ៣ : ក្រុមការងារអភិបាលកិច្ច មានបេសកកម្ម មុខងារ និង ភារកិច្ចដូចតទៅ :

-ប្រមូលផ្តុំពតិមាន កម្មវិធី និង ផែនការសកម្មភាពរបស់ក្រុមប្រឹក្សាកំណែទំរង់នានា និង ក្រសួង-ស្ថាប័នពាក់ព័ន្ធ ។

-រៀបចំបង្កើតផែនការសកម្មភាពអភិបាលកិច្ច និង ឯកសារដទៃទៀតរបស់រាជរដ្ឋាភិបាល ដែលពាក់ព័ន្ធនឹងការងារអភិបាលកិច្ចល្អ ។

-តាមដាន និង ត្រួតពិនិត្យ អំពីភាពជឿនលឿននៃការអនុវត្តនីផែនការសកម្មភាពអភិបាលកិច្ច និង កម្មវិធីកំណែទំរង់នានា ។

-ផ្តល់យោបល់លើការងារបច្ចេកទេស ក្នុងក្របខ័ណ្ឌអភិបាលកិច្ច និង កំណែទំរង់ ដល់ក្រុមប្រឹក្សាកំណែទំរង់នានា និង ក្រសួងពាក់ពន្ធ័ ។

-ធ្វើការសំរបសំរួល និង ទំនាក់ទំនងយ៉ាងជិតស្និទ្ធ ជាមួយក្រុមការងាររបស់ក្រុមប្រឹក្សាកំណែទំរង់នានា និង ក្រសួងពាក់ពន្ធ័ ។

-ធ្វើរបាយការណ៍ និង បូកសរុបការងារជាប្រចាំ ជូនទីស្តីការគណៈរដ្ឋមន្ត្រី និង ប្រធានឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ ។

ប្រការ ៤ : ក្រុមការងារនេះ ត្រូវបំពេញ និង ប្រតិបត្តិការងារ ដោយមាន ៦ ផ្នែកជាចំណុះ ទៅតាមតំរូវការដូចខាងក្រោម :

**-ផ្នែកកំណែទំរង់រដ្ឋបាលសាធារណៈ**

**-ផ្នែកកំណែទំរង់ច្បាប់ និង ប្រព័ន្ធយុត្តិធម៌**

**-ផ្នែកកំណែទំរង់ និង រំសាយកងកំលាំងប្រដាប់អាវុធ**

**-ផ្នែកកំណែទំរង់សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**-ផ្នែកអភិវឌ្ឍន៍សង្គមកិច្ច និង ការងារចេនឌ័រ**

**-ផ្នែកគ្រប់គ្រងធនធានធម្មជាតិ**

**-ផ្នែកទំនាក់ទំនងសាធារណៈ**

ប្រការ ៥ : ក្រុមការងារនេះ ត្រូវដឹកនាំដោយប្រធាន ១ រូប និង អនុប្រធាន មួយចំនួន តាមតំរូវការចាំបាច់ជាជំនួយការ ។ ប្រធានក្រុមការងារ ត្រូវតែងតាំងដោយព្រះរាជក្រឹត្យ ឬ អនុក្រឹត្យ តាមតំរូវការ

ចាំបាច់របស់រាជរដ្ឋាភិបាល ។ អនុប្រធានក្រុមការងារ និង ប្រធានផ្នែកនីមួយៗ ត្រូវតែងតាំងដោយអនុក្រឹត្យ ឬ ប្រកាស តាមតំរូវការចាំបាច់របស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

**ប្រការ ៦ :** ចំនួនផ្នែករបស់ក្រុមការងារអភិបាលកិច្ច អាចបង្កើន ឬ បន្ថយតាមតំរូវការចាំបាច់ ដោយប្រកាសរបស់រដ្ឋមន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី ។

**ប្រការ ៧ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធានក្រុមប្រឹក្សាកំណែទំរង់ទាំង ៧ ចំណុះឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ រដ្ឋមន្ត្រី រដ្ឋលេខាធិការ ក្រុមប្រឹក្សាអាជ្ញាធរជាតិ គ្រប់ក្រសួង-ស្ថាប័ន ត្រូវទទួលអនុវត្តសេចក្តីសំរេចនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខា នេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ប្រធានឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ**

**ហ៊ុន សែន**

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី សូមចុះហត្ថលេខា

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**និង ជាប្រធានក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល**

**សុខ អាន**

*កន្លែងទទួល:*

*-ក្រសួងព្រះបរមរាជវាំង*

*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*

*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*

*-ឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ*

*-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*

*-ដូចប្រការ ៨*

*-កាលប្បវត្តិ-ឯកសារ*